# អនុក្រឹត្យ

## ស្តីពី

## បែបបទសំរាប់អនុវត្តចំពោះការអនុញ្ញាត
## អោយជនបរទេស មិនមែនអន្តោប្រវេសន្ត
## ចូល ចេញ និងស្នាក់អាស្រ័យនៅ
## ព្រះរាជាណាចក្រកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៧៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## បែបបទសំរាប់អនុវត្តចំពោះ ការអនុញ្ញាតអោយជនបរទេស មិនមែន អន្តោប្រវេសន្ត ចូល ចេញ និង ស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស - រកត- ១១៩៨- ៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២-នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកត-០១៩៦-០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

-បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ០៥-នស-៩៤ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីអន្តោប្រវេសន៍

-បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី ០៦ខែ សីហា ឆ្នាំ ១៩៩៩

### សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីបែបបទសំរាប់ការចូល ចេញ និង ស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជានៃជនបរទេសមិនមែនអន្តោប្រវេសន្ត ដូចមានចែងក្នុងមាត្រា ៧ នៃច្បាប់ស្តីពីអន្តោប្រវេសន៍ លើកលែងតែជនបរទេសដែលរស់នៅតាមព្រំប្រទល់ជាប់នឹងខេត្តនានានៃព្រះរាជាណាចក្រកម្ពុជា ដែលជាកម្មវត្ថុនៃអនុក្រឹត្យ ដោយឡែក ។

## ជំពូកទី ២

## បែបបទសំរាប់ការចូល ចេញ ព្រះរាជាណាចក្រកម្ពុជា

**មាត្រា២.-**

ជនបរទេសមិនមែនអន្តោប្រវេសន្តទាំងឡាយណា ដែលមានបំណងចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវដាក់ពាក្យស្នើសុំទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជា តាមរយៈស្ថានបេសកកម្មទូត ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ឬ តាមរយៈស្ថានតំណាងផលប្រយោជន៍ នៃពះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ។

ចំពោះជនបរទេស ដែលកាន់លិខិតឆ្លងដែនចេញអោយ ដោយប្រទេសទាំងឡាយណា ដែលមានចែងក្នុងបញ្ជីកំណត់ដោយក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និង ក្រសួងមហាផ្ទៃ ព្រមទាំង ទេសចរ យានិក នាវិក អ្នកដំណើរឆ្លងកាត់ និង ជនដែលមានសញ្ជាតិដើមជាខ្មែរ រួមទាំងសហព័ទ្ធ និង កូនអាចធ្វើពាក្យសុំទិដ្ឋាការចូលនៅនឹងចំណុចច្រកទ្វារអន្តរជាតិ ដែលកំណត់ដោយរាជរដ្ឋាភិបាល ។

**មាត្រា៣.-**

ការស្នើសុំទិដ្ឋាការត្រូវបំពេញបែបបទដូចតទៅ :

១-បំពេញពាក្យសុំទិដ្ឋាការ ។

២-បង្ហាញលិខិតឆ្លងដែនរបស់ខ្លួន ឬ ឯកសារណាមួយដែលមានតម្លៃស្មើគ្នា និង ដែលមាន សុពលភាពយ៉ាងតិច បី ខែ មុនថ្ងៃបញ្ចប់ការស្នាក់នៅព្រះរាជាណាចក្រកម្ពុជា ។

៣-ផ្តល់រូបថត ៤ x ៦ ចំនួន ៣ សន្លឹក ។

៤-បង់អាករតាមការកំណត់ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ។ អាករទិដ្ឋាការនេះមិនត្រូវបានសងវិញទេ ទោះក្នុងករណីនៃការស្នើសុំទិដ្ឋា ការនោះត្រូវបានបដិសេធក៏ដោយ ។

កុមារអាយុក្រោម ១២ ឆ្នាំ ធ្វើដំណើរជាមួយឪពុកម្តាយ ឬ អាណាព្យាបាលមិនចាំបាច់បំពេញបែបបទ ដោយឡែកទេ តែត្រូវចុះឈ្មោះរួមជាមួយឪពុកម្តាយ ឬអាណាព្យាបាលរបស់ខ្លួន ។

## ជំពូកទី ៣

## ប្រភេទទិដ្ឋាការ រយៈពេល និង អាករទិដ្ឋាការ

<u>មាត្រា៤</u>.-

ទិដ្ឋាការអាចជាទិដ្ឋាការប្រើសំរាប់ចូល ចេញ មួយដង ឬ ច្រើនដង ។

ប្រភេទនៃទិដ្ឋាការរួមមាន :

១-**ទិដ្ឋាការការទូត** កំណត់សំគាល់ដោយអក្សរឡាតាំងធំ A ។ ទិដ្ឋាការនេះសំរាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត និង ក្រុមគ្រួសាររបស់គេ ដែលកាន់លិខិតឆ្លងដែនការទូត ហើយមកបំពេញបេសកកម្មការទូត ឬ ក្នុងលក្ខណៈឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ អាចត្រូវបានផ្តល់ចំពោះជនបរទេសដទៃទៀត ដែលមានការសំរេចពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

២-**ទិដ្ឋាការផ្លូវការ** កំណត់សំគាល់ដោយអក្សរឡាតាំងធំ B ។ ទិដ្ឋាការនេះសំរាប់ផ្តល់ ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលមកបំពេញបេសកកម្មក្នុងក្របខ័ណ្ឌរដ្ឋ ឬ ក្នុងក្របខ័ណ្ឌអង្គការអន្តរជាតិនានា ដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។ ទិដ្ឋាការនេះក៏សំរាប់ផ្តល់ក្នុងលក្ខណៈឯកជនដែរ ចំពោះជនបរទេសណាដែលកាន់លិខិតឆ្លងដែនផ្លូវការ ។

៣-**ទិដ្ឋាការសេរីភាព** កំណត់សំគាល់ដោយអក្សរឡាតាំងធំ C ។ ទិដ្ឋាការនេះ សំរាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ព្រមទាំងក្រុមគ្រួសាររបស់គេ ដែលក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ឬ ក្រសួងនានាចាត់ទុក ថាជាការសំដែងនូវការគួរសម ។ ទិដ្ឋាការនេះក៏សំរាប់ផ្តល់ចំពោះគ្រួសារជនបរទេសមិនមែនអន្តោប្រវេសន្តក្នុងចំណុចទី ២ មាត្រា ៤ នៃអនុក្រឹត្យនេះ ។

៤-**ទិដ្ឋាការទេសចរណ៍** កំណត់សំគាល់ដោយអក្សរឡាតាំងធំ T ។ ទិដ្ឋាការនេះ សំរាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តដែលជាទេសចរ ។

៥-**ទិដ្ឋាការឆ្លងកាត់** កំណត់សំគាល់ដោយអក្សរឡាតាំងធំ D ។ ទិដ្ឋាការនេះ សំរាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលជាអ្នកធ្វើដំណើរឆ្លងកាត់ ដែលជាអ្នកបើកបរ ជាបុគ្គលិក កម្មករ នាវា ឬ យន្តហោះ ។

៦-**ទិដ្ឋាការធម្មតា** កំណត់សំគាល់ដោយអក្សរឡាតាំងធំ E ។ ទិដ្ឋាការនេះសំរាប់ ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តទាំងឡាយណាដែលគ្មានរាប់ចូលក្នុង ប្រភេទទិដ្ឋាការណាមួយដូចខាងលើនេះ ។

៧-**ទិដ្ឋាការពិសេស** កំណត់សំគាល់ដោយអក្សរឡាតាំងធំ K ។ ទិដ្ឋាការ នេះសំរាប់ផ្តល់ចំពោះជនដែលមានសញ្ជាតិដើមជាខ្មែរ ហើយកាន់ឯកសារធ្វើ ដំណើរបរទេស ។ ទិដ្ឋាការនេះចេញអោយដោយពុំមានបង់អាករទិដ្ឋាការ អាច ចេញ ចូល ច្រើនដងបាន ហើយ មានរយៈពេលស្នាក់នៅមិនកំណត់ ។

**<u>មាត្រា៥.-</u>**

ទិដ្ឋាការ A B C T D និង E មានសុពលភាព បី ខែ ដោយគិតចាប់តាំងពីថ្ងៃចេញទិដ្ឋាការនោះ ។ បើផុតរយៈពេល បី ខែ ត្រូវសុំទិដ្ឋាការថ្មី ។ ទិដ្ឋាការពិសេស K មានសុពលភាពមិនកំណត់ ។

ជនបរទេសដែលត្រូវបានអនុញ្ញាតអោយចូលព្រះរាជាណាចក្រកម្ពុជាតាមរយៈទិដ្ឋាការ ដែលផ្តល់ដំបូងអាចស្នាក់នៅ :

- បីខែ ចំពោះទិដ្ឋាការប្រភេទ A B និង C
- មួយខែ ចំពោះទិដ្ឋាការប្រភេទ T និង E
- ប្រាំថ្ងៃ ចំពោះទិដ្ឋាការប្រភេទ D ។

ការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្នត្រូវអនុវត្តតាមការកំណត់ដូចមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យនេះ ។

មាត្រា៦.-

មូលហេតុនៃការស្នាក់នៅជាក់ស្តែង ត្រូវតែស្របតាមប្រភេទនៃទិដ្ឋាការដែលចេញអោយ ។

មាត្រា៧.-

អាករទិដ្ឋាការត្រូវកំណត់ដូចខាងក្រោម :

- ទិដ្ឋាការ ការទូត A មិនយកអាករ
- ទិដ្ឋាការ ផ្លូវការ B មិនយកអាករ
- ទិដ្ឋាការ ពេរីភាព C មិនយកអាករ
- ទិដ្ឋាការ ទេសចរណ៍ T អាករស្មើនឹង ម្ភៃ ដុល្លារអាមេរិក
- ទិដ្ឋាការ ឆ្លងកាត់ D អាករស្មើនឹង ដប់ប្រាំដុល្លារអាមេរិក
- ទិដ្ឋាការ ធម្មតា E អាករស្មើនឹង ម្ភៃប្រាំដុល្លារអាមេរិក
- ទិដ្ឋាការពិសេស K មិនយកអាករ ។

## ជំពូកទី ៤
## ការចេញ ការពន្យារ ការបដិសេធន៍ ទិដ្ឋាការ និង ការស្នាក់នៅបណ្តោះអាសន្ន

មាត្រា៨.-

រយៈពេលបន្តការស្នាក់នៅបណ្តោះអាសន្នត្រូវបានកំណត់ដូចតទៅ :

- ទិដ្ឋាការ ការទូត A អាចបន្តបានពីមួយខែ ដល់ ដប់ពីរខែម្តងរហូតដល់ចប់បេសកកម្ម
- ទិដ្ឋាការ ផ្លូវការ B អាចបន្តបានពីមួយខែដល់ដប់ពីរខែម្តងយ៉ាងយូររហូតដល់ចប់បេសកកម្ម
- ទិដ្ឋាការ ពេរីភាព C អាចបន្តបានពីមួយខែ ដល់ ដប់ពីរខែម្តងយ៉ាងយូរ
- ទិដ្ឋាការ ទេសចរណ៍ T អាចបន្តបានមួយដង និង មិនលើសពី ៣០ ថ្ងៃ សំរាប់ការចេញ ចូល តែមួយដង

- ទិដ្ឋាការ ឆ្លងកាត់ D មិនអាចបន្តបានទេ លើកលែងតែក្នុងករណីប្រធានសក្តិ
- ទិដ្ឋាការ ធម្មតា E អាចបន្តបាន ពីមួយខែ ដល់ ដប់ពីរខែ ដោយសាមីជនត្រូវមក បង្ហាញខ្លួន ដើម្បីបំពេញបែបបទ ដោយផ្ទាល់នៅស្ថាប័នមានសមត្ថកិច្ចរបស់ក្រសួង មហាផ្ទៃ។

  ចាប់ពីមួយឆ្នាំឡើងទៅសាមីជន ត្រូវសុំប័ណ្ណស្នាក់នៅបណ្តោះអាសន្នពីស្ថាប័ន ខាងលើ ។
- ទិដ្ឋាការពិសេស K មានរយៈពេលស្នាក់នៅមិនកំណត់ ។

<u>មាត្រា៩</u>.-

បែបបទស្នើសុំការអនុញ្ញាតបន្តស្នាក់នៅបណ្តោះអាសន្នមានដូចតទៅ :

១-បំពេញពាក្យសុំបន្តស្នាក់នៅបណ្តោះអាសន្ន ។

២-ភ្ជាប់មកជាមួយនូវលិខិតឆ្លងដែន ដែលនៅមានសុពលភាពយ៉ាងតិចបីខែ លើស រយៈពេលស្នើសុំបន្តស្នាក់នៅបណ្តោះអាសន្ន ។

៣-រូបថត ៤ x ៦ ចំនួន មួយ សន្លឹក ។

៤-ត្រូវបង់អាករសំរាប់ការអនុញ្ញាតបន្តស្នាក់នៅបណ្តោះអាសន្នតាមការកំណត់ក្នុង មាត្រា ១១ នៃអនុក្រឹត្យនេះ ។

៥-ចំពោះទិដ្ឋាការធម្មតា E ដែលស្នើសុំការអនុញ្ញាតបន្តស្នាក់នៅបណ្តោះអាសន្ន ចាប់ពីប្រាំមួយខែឡើងទៅ ត្រូវមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័ននានាបញ្ជាក់ថា ពិតជាមានការចាំបាច់ក្នុងការបន្តស្នាក់នៅបណ្តោះអាសន្នមែន ឬ កិច្ចសន្យាការងារ ជាមួយរោងចក្រ សហគ្រាស ក្រុមហ៊ុន សិប្បកម្ម ឬ ការដ្ឋាន ដែលមានការទទួល ស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និង ការងារ ឬ លិខិតបញ្ជាក់ស្តីពី ការចុះបញ្ជីពាណិជ្ជកម្មដែលចេញអោយដោយក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណា ចក្រកម្ពុជា ។

<u>មាត្រា១០</u>.-

ក- ស្ថានបេសកកម្មការទូត ឬ កុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ឬ ស្ថាន តំណាងផលប្រយោជន៍ នៃព្រះរាជាណាចក្រកម្ពុជានៅបរទេសមានសមត្ថកិច្ច ចេញទិដ្ឋាការ គ្រប់ប្រភេទ ។

ខ- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិមានសមត្ថកិច្ច :

- ចេញ និង បដិសេធទិដ្ឋាការប្រភេទ AB និង C
- អនុញ្ញាតបន្តការស្នាក់នៅបណ្តោះអាសន្នសំរាប់ទិដ្ឋាការប្រភេទ AB និង C
- កំណត់ការចេញ ចូលមួយ ឬ ច្រើនដងសំរាប់ទិដ្ឋាការប្រភេទ AB និង C ។

គ- ក្រសួងមហាផ្ទៃមានសមត្ថកិច្ច :

- ចេញទិដ្ឋាការប្រភេទ TDE និង K
- បន្តការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នចំពោះទិដ្ឋាការប្រភេទ TD និង E
- បដិសេធទិដ្ឋាការ និង ការអនុញ្ញាតបន្តស្នាក់នៅបណ្តោះអាសន្នចំពោះទិដ្ឋាការ ប្រភេទ TD និង E
- កំណត់ការចេញ ចូល មួយ ឬ ច្រើនដងសំរាប់ទិដ្ឋាការប្រភេទ TDE និង K ។

**មាត្រា១១.-**

អាករលើការអនុញ្ញាតបន្តស្នាក់នៅបណ្តោះអាសន្ន ត្រូវកំណត់ដូចខាងក្រោម :

-ស្មើនឹង សាមសិបដុល្លារ អាមេរិក សំរាប់ការអនុញ្ញាតបន្តស្នាក់នៅបណ្តោះអាសន្ន រយៈពេលក្រោម ឬ ស្មើ មួយខែ

-ស្មើនឹង ហុកសិបដុល្លារ អាមេរិក សំរាប់ការអនុញ្ញាតបន្តស្នាក់នៅបណ្តោះ អាសន្ន រយៈពេលបីខែ

-ស្មើនឹង មួយរយដុល្លារ អាមេរិក សំរាប់ការអនុញ្ញាតបន្តស្នាក់នៅបណ្តោះអាសន្ន រយៈពេលប្រាំមួយខែ

-ស្មើនឹង មួយរយប៉ែតសិបដុល្លារ អាមេរិកសំរាប់ការអនុញ្ញាតបន្តស្នាក់នៅបណ្តោះ អាសន្នរយៈពេលមួយឆ្នាំ ។

អាករលើការអនុញ្ញាតបន្តការស្នាក់នៅបណ្តោះអាសន្នខាងលើនេះ មិនអនុវត្តចំពោះប្រភេទ ទិដ្ឋាការ ABC និង K ទេ ។

**មាត្រា១២.-**

អាករគ្រប់ប្រភេទខាងលើត្រូវបង់ចូលថវិកាជាតិ ។

បែបបទនៃការប្រមូលអាករនេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ជំពូកទី ៥
## ការហាមឃាត់មិនអោយចូល និង
## មិនអនុញ្ញាតអោយស្នាក់នៅបណ្តោះអាសន្ន

<u>មាត្រា២៣</u>.-

ត្រូវហាមឃាត់មិនអោយចូល និង មិនអោយស្នាក់នៅបណ្តោះអាសន្នក្នុងព្រះរាជាណាចក្រកម្ពុជា ជនបរទេសមិនមែនអន្តោប្រវេសន្តណា ដែលមានមូលហេតុណាមួយដូចខាងក្រោមនេះ :

១- លិខិតឆ្លងដែន ឬ ឯកសារធ្វើដំណើរគ្មានតម្លៃ ។

២- គ្មានបោះត្រាបញ្ជាក់ការចូលប្រទេស ពីមន្ត្រីអន្តោប្រវេសន៍កម្ពុជាប្រចាំនៅច្រកទ្វារអន្តរជាតិ ឬ ទ្វារភាគីណាមួយ ។

៣- វិកលចរិត ។

៤- ទីទ័លក្រ មិនអាចចិញ្ចឹមខ្លួនឯង និង ក្រុមគ្រួសារខ្លួន ហើយដែលគ្មានជនណាផ្សេងសន្យាដោះស្រាយជំនួស ។

៥- ពាក់ព័ន្ធនឹងគ្រឿងញៀន ។

៦- ប្រកបរបរពេស្យាចារ ឬ ជំនួញពេស្យាកម្មផ្សេងៗទៀត ។

៧- ធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានប័ណ្ណការងារ ។

៨- ធ្លាប់បានបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានការអនុញ្ញាតពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ឬ ក្រសួងមហាផ្ទៃ ។

៩- គាំទ្រសកម្មភាពបំផ្លិចបំផ្លាញវប្បធម៌ទុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

១០- បានលួចឡើងជិះនាវា រថយន្ត ឬ យន្តហោះ មកចុះចតនៅព្រះរាជាណាចក្រកម្ពុជា ។

១១- ផ្តល់ជំនួយ ឬ ជួយលាក់បាំងក្នុងការបញ្ចូលជនបរទេសមិនស្របច្បាប់មកក្នុងព្រះរាជាណាចក្រកម្ពុជា ។

១២- គេចវេសពីការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋដែលសាមីខ្លួនបានប្រព្រឹត្ត ។

១៣- ត្រូវក្រសួងមានសមត្ថកិច្ច មានហេតុផលគ្រប់គ្រាន់ជឿថា នឹង ប្រព្រឹត្តសកម្មភាពធ្វើខូចផលប្រយោជន៍សាធារណៈ ឬ សន្តិសុខសាធារណៈ ។

១៤- ក្រសួងមានសមត្ថកិច្ចយល់ឃើញថាមិនចង់អោយមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជា ។

<u>មាត្រា១៨</u>.-

រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ឬ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចដិសេធចោលទិដ្ឋាការ និង ការអនុញ្ញាតអោយស្នាក់នៅបណ្តោះអាសន្នចំពោះមូលហេតុណាមួយដូចខាងក្រោម :

១- ម្ចាស់ទិដ្ឋាការបានរំលោភលើបទប្បញ្ញត្តិនានានៃច្បាប់ ស្តីពី អន្តោប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា ។

២- ម្ចាស់ទិដ្ឋាការត្រូវបានកាត់ទោសពីបទឧក្រិដ្ឋ ។

៣- ទិដ្ឋាការដែលបានមកដោយការក្លែងបន្លំ ឬ កោសលុប ។

៤- រដ្ឋមន្ត្រីទាំងពីរយល់ឃើញថាវត្តមានរបស់ម្ចាស់ទិដ្ឋាការ អាចបង្កអោយមានគ្រោះថ្នាក់ដល់សន្តិសុខជាតិ ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

<u>មាត្រា១៥</u>.-

ជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលស្នាក់នៅហួសរយៈពេលកំណត់ក្រោមសាមសិបថ្ងៃត្រូវបង្ខំអោយបង់ប្រាក់ពិន័យអន្តរការណ៍ប្រាំដុល្លារអាមេរិក ក្នុងមួយថ្ងៃ សំរាប់ថ្ងៃ ដែលលើសបូកនឹង អាករលើការអនុញ្ញាតបន្តការស្នាក់នៅបណ្តោះអាសន្នរយៈពេលមួយខែ ។

<u>មាត្រា១៦</u>.-

១- ជនបរទេសមិនមែនអន្តោប្រវេសន្តណា ដែលស្នាក់នៅហួសរយៈពេលកំណត់លើសពី សាមសិបថ្ងៃត្រូវបង្ខំអោយបង់ប្រាក់ពិន័យអន្តរការណ៍ ដោយអនុលោមទៅតាមមាត្រា ១៥ នៃអនុក្រឹត្យនេះហើយត្រូវបញ្ជាអោយចេញផុតពីព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៧ ថ្ងៃ យ៉ាងយូរ ។

២-ក្នុងករណីរឹងរូស ឬ គេចវេស មិនចេញពីកម្ពុជាតាមការកំណត់ដូចមានចែងក្នុងចំណុចទី ១ ខាងលើនេះ សាមីជនត្រូវបង្ខំអោយបង់ប្រាក់ពិន័យអន្តរការណ៍ទ្វេគុណ ហើយត្រូវឃាត់ខ្លួន ដើម្បីរៀបចំបែបបទបណ្តេញចេញតាមច្បាប់ស្តីពីអន្តោប្រវេសន៍ ។

**មាត្រា១៧.-**

១-ជនបរទេសមិនមែនអន្តោប្រវេសន្តណា ដែលល្មើសនឹងមាត្រា ៦ នៃអនុក្រឹត្យនេះហើយមានកម្មភាពផ្ទាល់ខ្លួនបង្ហាញថា បានប្រើប្រាស់ទិដ្ឋាការខុសពីប្រភេទដែលបានស្នើសុំត្រូវពិន័យអន្តរការណ៍ជាប្រាក់ស្មើនឹង មួយរយដុល្លារអាមេរិក ហើយត្រូវបញ្ជាអោយចេញផុតពីព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ប្រាំពីរថ្ងៃ យ៉ាងយូរ ។

២-ក្នុងករណីរឹងរូស ឬ គេចវេសមិនចេញពីកម្ពុជា តាមការកំណត់ដូចមានចែងក្នុងចំណុចទី១ ខាងលើនេះសាមីជនត្រូវបង្ខំអោយបង់ប្រាក់ពិន័យអន្តរការណ៍ទ្វេគុណ ហើយត្រូវឃាត់ ខ្លួន ដើម្បីរៀបចំបែបបទបណ្តេញចេញតាមច្បាប់ស្តីពីអន្តោប្រវេសន៍ ។

**មាត្រា១៨.-**

ប្រាក់ពិន័យអន្តរការណ៍ខាងលើនេះត្រូវបង់ចូលថវិកាជាតិ ។

បែបបទនៃការប្រមូលប្រាក់ពិន័យអន្តរការណ៍នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង របស់ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**មាត្រា១៩.-**

អនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពី បែបបទសំរាប់អនុវត្តចំពោះការអនុញ្ញាតអោយជនបរទេសមិនមែនអន្តោប្រវេសន្តចេញ ចូល និង ស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជានិង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

## មាត្រា២០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

**បានជំរាបជូន** **ហ៊ុន សែន**

**សម្តេចនាយករដ្ឋមន្ត្រី**

| សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | | រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
|---|---|---|---|
| ស ខេង | យូ ហុកគ្រី | ហោ ណាំហុង | គាត ឈន់ |

<u>កន្លែងទទួល</u>

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្តក្រុង
- ដូចមាត្រា២០
- ឯកសារ-កាលប្បវត្តិ